雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.181

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7923 ថ្ងៃសុក្រ ទី03 ខែឧសភា ឆ្នាំ2019

## ការហក់ឡើងនៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ



*កម្មករ ខ្មែរកំពុងធ្វើការយ៉ាងសប្បាយក្នុង រោងចក្រ (រូបថតដោយស៊ឺន យ៉ាន)*

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដែលមានទំហំជាងមួយពាន់ហិកតានោះ ជាតំបន់សេដ្ឋកិច្ចសហប្រតិបត្តិការអន្តរជាតិក្រុមទី១ របស់ប្រទេសចិ នដែលរួមគ្នាបណ្តាក់ទុនវិនិយោគ និងរៀបចំបង្កើតដោយក្រុមហ៊ុនហុងទូវ ខេត្តជាំងស៊ូ ប្រទេសចិន និងសហគ្រាសមួយចំនួនទៀត ។ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ជាគម្រោងគំរូមួយតាមបណ្តោយ"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។ គម្រោងនេះមិនគ្រាន់តែបានឆ្លុះបញ្ចាំងពីចំណងមិត្តភាពដ៏ល្អប្រពៃរវាងប្រទេសចិននិងកម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញឱ្យឃើញពីគោលការណ៍"រួមគ្នាពិគ្រោះពិភាក្សាស្ថាបនានិងចែករំលែកគ្នា"នៃគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។

លោកឆាវ ជីនជាំង អគ្គនាយកនៃក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានគូសបញ្ជាក់ថា ការអភិវឌ្ឍនៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុបានទាក់ទាញសហគ្រាស ដ៏ច្រើនសន្ធឹកសន្ធាប់ ។ គិតមកដល់ពេលនេះ សហគ្រាសចំនួនជាង ១៣០ ដែលមកពីប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង អឺរ៉ុបនិងអាម៉េរិកជាដើមបានសម្រេចនូវការអភិវឌ្ឍបែបឈ្នះ-ឈ្នះតាមរយៈតំបន់សេដ្ឋកិច្ចពិសេសនេះ ។ សព្វថ្ងៃមានសហគ្រាសចំនួន ១១៣ បានចាប់ផ្តើមធ្វើអាជីវកម្មជាផ្លូវការដែលបានផ្តល់ឱកាសការងារដល់ប្រជាជនខ្មែរជាង ២,១ ម៉ឺននាក់ ។

ក្រុមហ៊ុនកាបូបអេវើរវីន(ខេមបូឌា) ជាសាខាក្រុមហ៊ុននៃក្រុមហ៊ុនផានយូ គ្រុប ខេត្តជាំងស៊ូ ។ ក្រុមហ៊ុននេះបានចូលធ្វើអាជីវកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុក្រោយពីគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ត្រូវបានលើកឡើងជាផ្លូវការ ។ អ្នកទទួលខុសត្រូវនៃក្រុមហ៊ុននេះបានសម្រេចទៅធ្វើវិនិយោគនៅប្រទេសកម្ពុជា ដោយសារមានទំនុកចិត្តលើគំនិតផ្តួចផ្តើមដ៏អស្ចារ្យនេះ ។ លោកស្រីសាវស្យេវយី អគ្គនាយកក្រុមហ៊ុនបានប្រាប់អ្នកកាសែតថា ក្រុមហ៊ុនយើងខ្ញុំចាប់ធ្វើអាជីវកម្មតាំងពីខែមករា ឆ្នាំ២០១៥ ហើយចាប់ផ្តើមបានចំណេញពីខែមករា ឆ្នាំ២០១៨ ។ ក្រុមហ៊ុនយើងទទួលបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់កម្មករក៏អាចទទួលចំណូលកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាពិសេសក្រុមហ៊ុនបានផ្តល់ឱកាសការងារដល់ប្រជាជនខ្មែរ ៧០០នាក់ ។

កញ្ញាសុខ ធីវ៉ា មានអាយុ ២៦ ឆ្នាំហើយ។ គាត់រស់នៅក្នុងភូមិមួយដែលស្ថិតនៅក្បែរតំបន់សេដ្ឋកិច្ចពិសេសក្រុង ព្រះសីហនុហើយបានមកធ្វើការនៅក្រុមហ៊ុនរ៉ូមេនធីក លេឌើរ (ខេមបូឌា) ។ ការងារនេះបានធ្វើឱ្យគាត់សប្បាយចិត្តយ៉ាងខ្លាំង ។ គាត់បានប្រាប់អ្នកកាសែតថា កាលមុនសមាជិកទាំងអស់នៃគ្រួសារខ្ញុំសុទ្ធតែប្រកបរបរកសិកម្ម ហើយបានចំណូលមិនច្រើនទេ។ តែឥឡូវ ក្នុងគ្រួសារខ្ញុំមាន៨នាក់ ក្រៅពីក្មេងម្នាក់ដែលកំពុងចូលរៀននៅសាលានៅ សល់៧នាក់ សុទ្ធតែមកធ្វើការនៅតំបន់សេដ្ឋកិច្ចពិសេសនេះ ។ យើងអាចបានប្រាក់ខែច្រើនជាងមុន ហើយមានជីវភាពកាន់តែធូរធារ ។

តាំងពីពេលដំបូងនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេសរហូតដល់បច្ចុប្បន្ននេះ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានប្រកាន់ខ្ជាប់នូវទស្សនៈនិងគោលការណ៍"ឈ្នះ-ឈ្នះ៨ ភាគី" រួមមានម្ចាស់ហ៊ុនបុគ្គលិកការងារអតិថិជន អ្នកផ្គត់ផ្គង់ ដៃគូសហប្រតិបត្តិការ រដ្ឋាភិបាល បរិស្ថាននិងសហគមន៍ប្រជាជន ។ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុបានផ្តល់ឱកាសការងារច្រើនដល់ប្រជាជនខ្មែរលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរផ្តល់ជំនួយឧបត្ថម្ភដល់សិស្សនិស្សិតសាងសង់ស្ពាននិងផ្លូវថ្នល់និងជួយប្រជាជនក្រីក្រដើម្បីផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជនក្នុងតំបន់ ។ ការរីកចម្រើននៃតំបន់សេដ្ឋកិច្ចពិសេសបានធ្វើឱ្យការរស់នៅរបស់ប្រជាជនក្នុងតំបន់ប្រែមុខប្រែមាត់យ៉ាងខ្លាំង ។

គោលនយោបាយលើកទឹកចិត្តហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់និងការអភិវឌ្ឍយ៉ាងឆាប់រហ័សបានធ្វើឱ្យអ្នកដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មានទំនុកចិត្តចំពោះអនាគត ។ ក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ ទោះបីជាលោកអ្នកទៅទស្សនាសហគ្រាសណាមួយក៏ដោយ ក៏អាចស្តាប់ឮពាក្យសម្តីដូចគ្នាគឺ"តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុនឹងអាចមានអនាគតកាន់តែភ្លឺស្វាង"៕

**ដោយៈ ស្យូងយ៉ាន ស៊ឺនយ៉ាន ហ្វឹងយ៉ាស្យេន និងយូ ជាំងនីង**

## ខេត្តយូណានផ្តល់អាទិភាពដល់ការកែលម្អបរិយាកាសពាណិជ្ជកម្ម

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៩ ទីស្តីការគណៈកម្មាធិការបក្សកុម្មុយនិស្តចិនខេត្តយូនណាននិងសាលារដ្ឋបាលខេត្តយូនណាន បានប្រកាស "មតិមួយចំនួនអំពីការកែលម្អបរិយាកាសពាណិជ្ជកម្មខេត្តយូនណាន"និង "ប្រតិបត្តិការសំខាន់ទាំង១០ សម្រាប់កែលម្អបរិយាកាសពាណិជ្ជកម្មខេត្តយូនណាន" ។ ពេលថ្មីៗនេះ សាលារដ្ឋបាលខេត្តយូណានបានប្រកាសព័ត៌មាន និងបកស្រាយអំពីលិខិតស្នាមខាងលើដើម្បីឆ្លើយតបនឹងការយកចិត្តទុកដាក់ពីសំណាក់ប្រជាជន ។

គណៈកម្មាធិការបក្សកុម្មុយនិស្តចិនខេត្តយូនណាន និងសាលារដ្ឋបាលខេត្តយូណាន យកចិត្តទុកដាក់កម្រិតខ្ពស់ដល់ការកែលម្អបរិស្ថានពាណិជ្ជកម្ម ហើយបានកំណត់យកឆ្នាំ២០១៩ជា"ឆ្នាំកែលម្អបរិស្ថានពាណិជ្ជកម្ម"ព្រមទាំងបានដាក់ចេញនូវ"មតិមួយចំនួនអំពីការកែលម្អបរិយាកាសពាណិជ្ជកម្មខេត្តយូនណាន"និង"ប្រតិបត្តិការសំខាន់ទាំង ១០ សម្រាប់កែលម្អបរិយាកាសពាណិជ្ជកម្មខេត្តយូនណាន"។

"មតិមួយចំនួនអំពីការកែលម្អបរិយាកាសពាណិជ្ជកម្មខេត្តយូនណាន" បានកំណត់វិធានការជាក់ស្តែង៣០ប្រការដែលគ្របដណ្តប់លើវិស័យ ចំនួន ៨ គឺទី១- លុបចោលទាំងស្រុងនូវការដាក់កំហិតមិនសមហេតុផលដើម្បីបង្កើតបរិយាកាសទីផ្សារដែលមានភាពស្មើគ្នាក្នុងការប្រកួតប្រជែង ។ ទី២-បន្តលើកកម្ពស់គុណភាពនៃសេវាកម្មផ្តល់សច្ចាប័ន និងប្រសិទ្ធភាពនៃការធ្វើការងារ ។ ទី៣-សម្រាលបន្ទុកពន្ធដាររបស់សហគ្រាសបន្ថយដើមទុននៃការធ្វើអាជីវកម្ម។ទី៤-ផ្តោតសំខាន់ទៅលើបញ្ហាដែលយកចិត្តទុកដាក់ដោយសហគ្រាសផ្តល់កិច្ចធានាពេញលក្ខណៈ។ ទី៥-ផ្តោតសំខាន់និងកំណត់ស្តង់ដារលើការអនុវត្តនិងការពិនិត្យតាមដានថែរក្សាសណ្តាប់ធ្នាប់យ៉ាងល្អប្រសើរ ។ ទី៦-ខិតខំការពារកម្មសិទ្ធិបង្កើតបរិយាកាសល្អប្រសើរសម្រាប់ការបង្កើតមុខជំនួញ និងការច្នៃប្រឌិតថ្មី ។ ទី៧-ខិតខំធ្វើសាមញ្ញកម្មសម្រាប់ទាក់ ទាញអ្នកវិនិយោគបរទេសនិងការធ្វើពាណិជ្ជកម្មពង្រឹងសមត្ថភាពសម្រាប់ ផ្តល់កិច្ចធានាដល់ការបើកចំហចំពោះបរទេស ។ ទី៨-ផ្តល់អាទិភាពដល់ ប្រព័ន្ធដឹកនាំបង្កើតបរិយាកាសយ៉ាង ល្អប្រសើរ។

"ប្រតិបត្តិការសំខាន់ទាំង ១០ សម្រាប់កែលម្អបរិយាកាសពាណិជ្ជកម្មខេត្តយូនណាន" បានកំណត់វិធានការជាក់ស្តែង ៤៦ ប្រការ ដែលគ្របដណ្តប់លើវិស័យចំនួន១០ រួមមានប្រតិបត្តិការ" បញ្ជីឈ្មោះចំនួន៦"អំពីសេវាកម្មរដ្ឋាភិបាល ប្រតិបត្តិការ"វិធានការ ១ចំនួន ៦"អំពីកំណែទម្រង់នៃការធ្វើវិមជ្ឈការគ្រប់គ្រងចម្រុះនិងកែលម្អសេវាកម្ម ប្រតិបត្តិការ"ស្មើភាពគ្នាទាំង៥វិស័យ" សម្រាប់លើកកម្ពស់តួនាទីសហគ្រាស ប្រតិបត្តិការ"កែលម្អទាំង៥ វិស័យ" អំពីការផ្តល់ថាមពលអគ្គិសនីឧស្ម័ន និងទឹកដល់សហគ្រាសការបង់ពន្ធ និងការចុះបញ្ជីអចលនទ្រព្យ ប្រតិបត្តិការ "ពន្លឿនដំណើរទាំង៥ "អំពីការធ្វើវិនិយោគនិងពាណិជ្ជកម្មប្រតិបត្តិការ" លេខសូន្យទាំង៤"អំពីការលើកកម្ពស់សេវាកម្មសហគ្រាសប្រតិបត្តិការ" ប្រកាសជាសាធារណៈទាំង៤វិស័យ" សម្រាប់ជំរុញការអភិវឌ្ឍនៃសហគ្រាសប្រតិបត្តិការ"ផ្តល់ការងាយស្រួលទាំង ៤វិស័យ"សម្រាប់ការពារសិទ្ធិសហគ្រាសប្រតិបត្តិការ"ត្រួតពិនិត្យទាំង៤វិស័យ" ក្នុងដំណើរអនុវត្តន៍ និងក្រោយពីការអនុវត្តនិងប្រតិបត្តិការ" យន្តការ៣"សម្រាប់ជំរុញការអនុវត្តគោលនយោបាយសំខាន់។ លិខិតស្នាមនេះបានបញ្ជាក់ពីវិធានការជាក់ស្តែងសម្រាប់កែលម្អបរិស្ថានពាណិជ្ជកម្មនិងបានកំណត់ឱ្យបានច្បាស់លាស់នូវខ្លឹមសារ និងអ្នកទទួលខុសត្រូវចំពោះប្រតិបត្តិការនីមួយៗ។

"ប្រតិបត្តិការសំខាន់ទាំង១០" នេះ បានរៀបចំឡើងដោយយោងតាមបទដ្ឋានស្តង់ដារជាតិចិនហើយមានបទដ្ឋានស្តង់ដារខ្លះមានតួនាទីឈានមុខគេក្នុងប្រទេសចិន ។ **ដោយៈ ជូ ពាន និងទួន ស្យេវ-យូយ**

## ខេត្តយូណានខិតខំអភិវឌ្ឍន៍ផលិតផលទេសចរណ៍តាមរង្វង់ភាគខាងលិច



*ទេសចរបរទេសកំពុង ទស្សនាក្រុងបុរាណទូខឺជុងនៅមណ្ឌលឌីឈីង*

ពេលថ្មីៗនេះ លោក យាន់-ឈឹងហ្វា អភិបាលខេត្តយូណាន បានចូលរួមជាអធិបតីក្នុងកិច្ចប្រជុំស្តីពីការសិក្សាស្រាវជ្រាវផលិតផលទេសចរណ៍តាមរង្វង់ភាគខាងលិចនៃខេត្តយូនណាន ។ លោកបានសង្កត់ធ្ងន់ថា យើងត្រូវជំរុញឱ្យការកំណត់ផែនការដើរតួនាទីផ្តល់ការណែនាំកែលម្អបន្ថែមទៀត នូវគម្រោងអភិវឌ្ឍន៍ជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍កែលម្អប្រព័ន្ធសេវាកម្មពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ពន្លឿនដំណើរនៃការអភិវឌ្ឍផលិតផលទេសចរណ៍តាមរង្វង់ភាគខាងលិចខេត្តយូនណាន ខិតខំប្រឹងប្រែងដើម្បីជំរុញឱ្យខេត្តយូនណានក្លាយទៅជាតំបន់ទេសចរណ៍ដែលមានតែមួយគ្មានពីរលើពិភពលោក ។

លោកបានមានប្រសាសន៍ថា សណ្ឋានដីនិងលក្ខណៈភូគព្ភសាស្ត្រនៃតំបន់ភាគខាងលិចខេត្តយូនណាន មានលក្ខណៈពិសេសគួរឱ្យកត់សម្គាល់ ហើយមានទេសភាពធម្មជាតិដ៏ស្រស់ស្អាតមានជីវចម្រុះសម្បូរបែប និងមានវប្បធម៌ជនជាតិភាគតិចដ៏វិសេសវិសាល ។ តំបន់នេះជាតំបន់មួយដែលមានសក្តានុពលធំធេងក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍។ ក្រោយពីបានធ្វើការអភិវឌ្ឍអស់ពេលជាច្រើនឆ្នាំទីនេះបានក្លាយទៅជាទីដៅទេសចរណ៍ដ៏សំខាន់ដែលមានផ្លូវទេសចរណ៍គំរូជាច្រើនខ្សែនិងសម្បូរដោយរមណីយដ្ឋានទេសចរណ៍ល្បីឈ្មោះ ។

ការបង្កើតផលិតផលទេសចរណ៍តាមរង្វង់ភាគខាងលិចខេត្តយូនណាន (តឺឈីន-សាំងគ្រីឡាលីជាំង-តាលី-យូយលី-ធឹងឈុង-លូស្វយ-កុងសាន-តឺឈីន) នឹងអាចបង្រួបបង្រួមនូវធនធានទេសចរណ៍ពិសេសគ្រប់ប្រភេទនៅភាគខាងលិចនៃខេត្តយូនណាន រួមមានទេសភាពជ្រលងភ្នំ លើខ្ពង់រាប វាលស្មៅ លើភ្នំព្រឹល ក្រុងបុរាណ និងវប្បធម៌ជនជាតិភាគតិចជាដើមដើម្បីជំរុញការអភិវឌ្ឍន៍នៃវិស័យទេសចរណ៍នៅភាគខាងលិចខេត្តយូនណាន និងជំរុញការចរាចរដោយសេរីនូវមនុស្សទំនិញមូលនិធិ និងព័ត៌មានជាដើមដែលសុទ្ធតែជាធាតុផ្សំដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ។ វិធានការនេះនឹងអាចជំរុញការអភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌បច្ចេកវិទ្យានិងការកាត់បន្ថយភាពក្រីក្រដោយ ព្រមពេលជាមួយគ្នាហើយជំរុញឱ្យភ្នំបៃតងនិងទឹកបៃតងក្លាយទៅជាភ្នំមាស និងភ្នំប្រាក់ ព្រមទាំងមានសារសំខាន់យ៉ាងក្រៃលែងសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមក្នុងតំបន់ភ្នំតាមតំបន់ព្រំដែនខាងលិចនៃខេត្តយូនណាន ៕

**ដោយៈ លី សាវម៉េងនិង ស៊ឹង ស្យេវពួ**

## ពិធី"ស្លួងសំណាប"ទាក់ទាញទេសចរដ៏ច្រើន



ពេលថ្មីៗនេះពិធី"ស្លួងសំណាប"(តាមភាសាចិនហៅថា"បើកទ្វារសំណាប")ឆ្នាំ២០១៩ បានរៀបចំយ៉ាងអធិកអធមនៅស្រែរាងជណ្តើរសាម៉ាប៉ែក្នុងស្រុកហុងហឺ ។ ព្រឹកវេលាម៉ោង ១០ អ្នកស្រុកជនជាតិហានីបានជួបជុំគ្នានៅក្បែរស្រែរាងជណ្តើរច្រៀងចម្រៀង និងរាំរបាំប្រពៃណីជាមួយគ្នាដើម្បីសម្តែងនូវការគោរពចំពោះធម្មជាតិតាមរយៈការរៀបចំពិធីបុណ្យប្រពៃណីនេះ ៕

**ដោយចាំង ឈុង និងវ៉ាង ពាន**